# ព្រះរាជក្រម

នស/រកម/០៦០៧/០១៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៩ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ៩ នៃ
# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា មួយ.-**

មាត្រា ៩ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ត្រូវបាន ធ្វើវិសោធនកម្មដូចតទៅ :

**មាត្រា ៩.-ថ្មី**

អាជ្ញាធរអគ្គិសនីកម្ពុជាមានសមាជិកទាំងអស់ ៣ រូប ដែលក្នុងនោះមាន ១ រូបជាប្រធាន ។ ប្រធាននិងសមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើររបស់នាយករដ្ឋមន្ត្រី ។ សមាជិកនីមួយៗត្រូវមានអាណត្តិ ៣(បី)ឆ្នាំ ហើយត្រូវបញ្ចប់ក្នុងពេលខុសៗគ្នា លើកលែងតែក្នុងអាណត្តិដំបូង ដូចមានចែងក្នុងមាត្រា ៧២ នៃច្បាប់នេះ ។

សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា អាចត្រូវបានតែងតាំងសំរាប់អាណត្តិបន្តទៀតបាន ។



ក្នុងកំលុង ២(ពីរ)ឆ្នាំ ក្រោយការបញ្ចប់អាណត្តិរបស់ខ្លួន សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាមិនត្រូវចូលបម្រើការងារ ឬ ទំនាក់ទំនងជាទីប្រឹក្សា ឬ ជាអ្នកពិគ្រោះយោបល់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណណាមួយឡើយ ។

**មាត្រា ពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣/ល.០៧០៦.២៦៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
**ហត្ថលេខា**
**ស៊ុយ សែម**

លេខៈ ៧៥៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៧
**អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល**
**ឃុន ជិនកេន**